# ខ្លឹមសារសង្ខេបសាលដីកាលេខ២៤(២០១៩) បទដឹកជញ្ជូនសារធាតុញៀនឆ្លងដែន

# (ជំនុំជម្រះឡើងវិញ)

## ពាក្យគន្លឹះ៖ ធាតុផ្សំបទល្មើស ធាតុផ្សំអត្តនោម័ត (ដឹង), វិមតិសង្ស័យបានជាប្រយោជន៍

## ភស្តុតាងពីបរទេស

## ១. អង្គហេតុនិងប្រវត្តិនីតិវិធី

ក្នុងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ ជនជាតិអូស្ត្រាលីម្នាក់ឈ្មោះនាង Taylor អាយុ៤១ឆ្នាំ ត្រូវបានឃាត់ខ្លួនជាក់ស្តែងនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដកហូតបាន Heroin ចំនួន ១២៧៧ក្រាម (ភាពសុទ្ធ៦៣ភាគរយ)។ អង្គហេតុនេះ ត្រូវបានចោទប្រកាន់ពីបទដឹកជញ្ជូនខុសច្បាប់នូវសារធាតុញៀន (ឆ្លងដែន) តាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន។ សាលក្រមចំពោះមុខ របស់សាលាដំបូងរាជធានីភ្នំពេញ លេខ៥០កប២ ឆ្នាំ២០១៤ សម្រេចផ្តន្ទាទោស នាងជាប់គុក ២៣ឆ្នាំ និងពិន័យ៥០លានរៀល។ នាង មិនពេញចិត្តបានប្តឹងឧទ្ធរណ៍ក្នុងខែមិថុនា ឆ្នាំ២០១៤។ សាលាឧទ្ធរណ៍ តាមសាលដីកាលេខ១១៨ឆ្នាំ២០១៦ សម្រេចតម្កល់សាលក្រមលេខ៥០ ទុកជាបានការដដែល។ Taylor បានប្តឹងសាទុក្ខក្នុងខែមករា ឆ្នាំ២០១៧ ប្រឆាំងនឹងសាលាដីកាទាំងមូល។ ក្នុងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ តុលាការកំពូល បានបើកសវនាការ និងចេញសាលដីកាលេខ៣១៨ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨។ តុលាការកំពូលអះអាងអំពីមូលដ្ឋានជាច្រើន ក្នុងនោះ យោងដល់មាត្រា៤នៃក្រមព្រហ្មទណ្ឌ ស្តីពីចេតនា ហើយចង្អុលបង្ហាញថាមិនមានសំអាងហេតុគ្រប់គ្រាន់....នៃការពិរុទ្ធភាពលើជនជាប់ចោទ.......និងសម្រេចបញ្ជូនទៅឲ្យសាលាឧទ្ធរណ៍ជំនុំជម្រះឡើងវិញ។ សាលាឧទ្ធរណ៍ ក្នុងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ បានបើកសវនាការ និងចេញសាលដីកាលេខ២៤ក្រV ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

សាលាឧទ្ធរណ៍ បានពិចារណាថាលើភស្តុតាង រួមទាំងឯកសារភស្តុតាងរបស់តុលាការអូស្ត្រាលីនិងបានរកឃើញថា កាបូបដែល Taylor កាន់នោះមិនមែនជារបស់នាង នាងមិនបានរៀបចំសំភារៈក្នុងកាបូបទេ។ មិត្តរបស់ Nwoko (សហជនជាប់ចោទ) ជាអ្នកប្រគល់កាបូបដល់នាង។ នាងបានថតរូបកាបូបជាបញ្ញើទុក តែមិនបានឃើញថាមានសារធាតុញៀនដែរ។ កាបូបត្រូវបានដេរបិទ ដែលអ្នកល្មមៗមិនអាចមើលឃើញដោយភ្នែកទេ។ បន្ថែមពីលើនេះ Taylor មិនបានទទួលកម្រៃអ្វីពីការទទួលបញ្ញើកាបូបនេះផងដែរ។ នេះបង្កើតនូវមន្ទិលថាតើ Taylor មានចេតនាដឹកជញ្ជូន ដោយដឹងថាក្នុងកាបូប មានសារធាតុញៀន៖...*ហេតុនេះវិមតិសង្ស័យ ជាប្រយោជន៍ដល់ពិរុទ្ធជនរូបនេះ តាមមាត្រា៣៥១នៃក្រមនីតិវិធីព្រហ្ម*

*ទណ្ឌ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គប្បីឲ្យពិរុទ្ធជនរូបនេះរួចផុតបទចោទប្រកាន់ ព្រោះ Taylor មិនបានដឹង គ្មានចេតនាប្រព្រឹត្តិបទល្មើស...។*

ជនជាប់ចោទជាមេក្លោងឈ្មោះ Nwoko ក្នុងរឿងនេះ ធ្លាប់ប្រើល្បិចឲ្យជនជាប់ចោទម្នាក់ទៀត ដឹកជញ្ជូនសារធាតុញៀន ក៏ប៉ុន្តែអ្នកដឹកជញ្ជូននោះ ត្រូវបានតុលាការប្រទេសអូស្ត្រាលី សម្រេចឲ្យរួចផុតបទចោទប្រកាន់ ដោយសារគ្មានចេតនា។ ជាចុងក្រោយ សាលាឧទ្ធរណ៍បានពិចារណាលើការអះអាងថារបស់នគរបាល និងព្រះរាជអាជ្ញា ដែលថា Taylor គ្រាន់តែជាជនរងគ្រោះ។

**សម្រេច៖** ២. បដិសេធសាលដីកាលេខ១១៨ ដែលតម្កល់សាលក្រមលេខ៥០ (កន្លែងទោសទណ្ឌលើ Taylor) និង **៣.** សម្រេចឲ្យ Taylor រួចផុតពីបទចោទ៖ ដឹកជញ្ជូននូវសារធាតុញៀនខុសច្បាប់ (ឆ្លងដែន)។

## ៣. កំណត់សំគាល់

១. ក្នុងរឿងនេះ យើងគួរកត់សំគាល់ថា សាលាឧទ្ធរណ៍ទទួលយកភស្តុតាងពីបរទេសមកពិចារណាផងដែរ។ តុលាការបានយោងដល់សាលក្រមប្រទេសអូស្ត្រាលី ក៏ប៉ុន្តែ អនុលោមតាមមូលដ្ឋានអធិបតេយ្យភាព អះអាងថាមិនចងកាតព្វកិច្ចឲ្យគោរពដោយតុលាការកម្ពុជាទេ។ តុលាការទំនងជាចង់បង្ហាញថា Taylor ក៏ដូចជាជនដទៃដែរ ជាជនរងគ្រោះ ដោយល្បិចបោករបស់ Nwoko។

២. តុលាការបានសំអាងលើមាត្រា៣៥១ និងមាត្រា៣៨។ តាមសាលដីកានេះ មន្ទិលដែលនាំជាប្រយោជន៍ឈានទៅដោះលែង លុះត្រាតែមន្ទិលពាក់ព័ន្ធនឹងបញ្ហាធ្ងន់ធ្ងរ ដែលក្នុងសំណុំរឿងនេះ គឺធាតុផ្សំអត្តនោម័ត ដែលអាចនាំទៅរកការសន្និដ្ឋានថា ជនជាប់ចោទបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបទល្មើស។ សាលដីកាព្រហ្មទណ្ឌកំពូលយ៉ាងតិចចំនួនមួយ ដែលផ្អែកតាមវិមតិសង្ស័យ សម្រេចឲ្យជនជាប់ចោទ រួចផុតពីបទចោទប្រកាន់ (សាលដីកាតុលាការកំពូលលេខ២៥៦(២០១៣)ទំ.៧)។ វិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ នាំឲ្យការដោះលែង មិនត្រូវប្រើទូលាយ ឬក្នុងដំណាក់កាលដំបូងមុនពេលការស៊ើបអង្កេតបានបញ្ចប់ចប់ និងក្រោយពីការថ្លឹងថ្លែងនូវភស្តុតាងទាំងអស់ (ដោះនិងដាក់បន្ទុក) (សាលដីកាតុលាការកំពូល អវតក F36 កថា ៣៧៩)។

**៣.** ទីបញ្ចប់ក្រោយពីជាប់ពន្ធនាគារបាន ៦ឆ្នាំ Talyor ត្រូវបានដោះលែង។ រឿងនេះបណ្ដាលមកពីតុលាការជាន់ទាប មិនបានពិចារណាទាំងស្រុងនូវភស្តុតាង ឬមិនមានភស្តុតាងពេញលេញ។ តើនេះជាកំហុសនរណា? សិទ្ធិសេរីភាពចម្បង (សិទ្ធិសុវត្ថិភាពបុគ្គល) ត្រូវបានបំពារបំពាន។ ជនរងគ្រោះគួរតែទទួលបានសំណង និងមានអ្នកទទួលខុសត្រូវ ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ឲ្យបានហ្មត់ចត់។